ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈទន្តពេទ្យកម្ពុជា
ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ
លេខ.០០១.៧/១៥.....កទជ

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥

បទបញ្ជាផ្ទៃក្នុង
គណៈទន្តពេទ្យកម្ពុជា

ជំពូក ១
បេសកកម្ម

ប្រការ ១.~

គណៈទន្តពេទ្យកម្ពុជាមានបេសកកម្មអនុលោមទៅតាម ព្រះរាជក្រឹត្យលេខ នស/រកត ០៩០៥/៣៦៩ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈទន្តពេទ្យកម្ពុជា។

ជំពូក ២
ទីស្នាក់ការ

ប្រការ ២.~

ការិយាល័យក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ មានទីស្នាក់ការស្ថិតនៅផ្ទះលេខ ៦២F ផ្លូវលេខ ៥៩៨ សង្កាត់បឹងកក់ ២ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ។

ជំពូក ៣
អគ្គលេខាធិការដ្ឋាន

ប្រការ ៣.~

អគ្គលេខាធិការដ្ឋានស្ថិតនៅជាមួយ ការិយាល័យនៃក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ដែលមានអគ្គលេខាធិការ អគ្គលេខាធិការរង អគ្គហេរញ្ញិក អគ្គហេរញ្ញិករង និងលេខាធិការមួយចំនួនជាជំនួយ។

ប្រការ ៤.~

អគ្គលេខាធិការមានភារៈកិច្ចគ្រប់គ្រង និងដឹកនាំនូវវាល់ការងារជាប្រចាំរបស់ការិយាល័យក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ។

ជំពូក ៤
ការិយាល័យក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ

ប្រការ ៥.~

តួនាទី និងការៈកិច្ចលំអិត របស់សមាជិកការិយាល័យក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធដោយឡែក។

ប្រការ ៦.~

ការិយាល័យក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ធ្វើការប្រជុំជារៀងរាល់ខែ នៃសប្តាហ៍ទី១។

ក្នុងករណីចាំបាច់ ការប្រជុំអាចនឹងត្រូវធ្វើឡើង ក្រោមការកោះអញ្ជើញរបស់ប្រធាន ឬអគ្គលេខាធិការ តាមការស្នើសុំរបស់សមាជិកការិយាល័យ០៣(បី)រូប យ៉ាងតិច០៣(បី)ថ្ងៃមុនពេលប្រជុំ ដោយភ្ជាប់នូវរបៀបវារៈ នៃការប្រជុំច្បាស់លាស់តាមរយៈលិខិតអញ្ជើញ សារអេឡិចត្រូនិច ឬទូរស័ព្ទ។

ប្រការ ៧.~

រាល់ការប្រជុំ ត្រូវដឹកនាំដោយប្រធាន ឬអនុប្រធាន ក្នុងករណីប្រធានអវត្តមាន ដោយមានការប្រគល់សិទ្ធិជាលាយលក្ខអក្សរ សារអេឡិចត្រូនិច ឬទូរស័ព្ទ ទៅអនុប្រធាន ឬអគ្គលេខាធិការ ក្នុងករណីមិនអាចធ្វើជាលាយលក្ខអក្សរបាន។

ពេលបញ្ចប់ការប្រជុំនីមួយៗ ប្រធានអង្គប្រជុំត្រូវធ្វើការបូកសរុប និងកំណត់នូវរបៀបវារៈសម្រាប់ការប្រជុំលើកក្រោយ។

ជំពូក ៥
ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ

ប្រការ ៨.~

ការប្រជុំរបស់ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ត្រូវកំណត់ធ្វើឡើងរៀងរាល់៦ខែម្តង នៅសប្តាហ៍ទី៤ នៃខែមករា និងខែកក្កដា លើកលែងតែសន្និបាតបញ្ចប់អាណត្តិ២ឆ្នាំ និងអាណត្តិ៦ឆ្នាំ ដែលនឹងត្រូវកំណត់ដោយក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ។

ក្នុងករណីចាំបាច់ ការប្រជុំមួយអាចនឹងត្រូវធ្វើឡើង ក្រោមការកោះអញ្ជើញរបស់ប្រធាន ឬអគ្គលេខាធិការ តាមការស្នើសុំរបស់សមាជិកក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិយ៉ាងតិច ១០(ដប់)រូប ១៥(ដប់ប្រាំ) ថ្ងៃមុនពេលប្រជុំ ដោយភ្ជាប់នូវរបៀបវារៈ នៃការប្រជុំច្បាស់លាស់តាមរយៈលិខិតអញ្ជើញ ឬសារអេឡិចត្រូនិច។

ប្រការ ៩.~

ការប្រជុំរបស់ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ អាចប្រព្រឹត្តិទៅបានលុះត្រាតែមានសមាជិកវត្តមានយ៉ាងតិច ៥0%+១ នៃចំនួនសមាជិក ។

ក្នុងករណីអង្គប្រជុំ ពុំមានកូរ៉ុមគ្រប់ចំនួន ការប្រជុំត្រូវលើកទៅថ្ងៃក្រោយជាស្វ័យប្រវត្តិ។

ការិយាល័យក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ត្រូវធ្វើលិខិតអញ្ជើញជាថ្មីសម្រាប់ការប្រជុំលើកទី២។

ប្រការ ១0.~

ការប្រជុំលើកទី២ ត្រូវធ្វើឡើង១៥(ដប់ប្រាំ)ថ្ងៃបន្ទាប់ពីការកោះប្រជុំលើកទី១។ ក្នុងករណីនេះ ទោះពុំមានកូរ៉ុមគ្រប់ចំនួនក៏ដោយ អង្គប្រជុំត្រូវប្រព្រឹត្តិទៅដោយគ្មានលក្ខខណ្ឌ។

ប្រការ ១១.~

របៀបវារៈនៃការប្រជុំត្រូវបានរៀបចំឡើងដោយ អគ្គលេខាធិការ និងមានការឯកភាពពីសមាជិកអង្គប្រជុំរបស់ ការិយាល័យក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ។

ប្រការ ១២.~

របៀបវារៈណាមួយដែលសមាជិកក្រុមប្រឹក្សាចង់បញ្ចូលក្នុងកម្មវិធីប្រជុំ ត្រូវផ្ញើជូនអគ្គលេខាធិការឲ្យបាន១ខែ មុនការប្រជុំ ដើម្បីឲ្យអគ្គលេខាធិការធ្វើការជ្រើសរើសអាទិភាព ដាក់ជូនប្រធានពិនិត្យ និងសម្រេច។

ក្នុងករណីចាំបាច់ នៅពេលប្រជុំប្រធានអង្គប្រជុំមានសិទ្ធិបន្ថែមរបៀបវារៈផ្សេងៗទៀត។ សមាជិកក៏អាចស បន្ថែមរបៀបវារៈណាមួយ បើមានការឯកភាពពីប្រធាន។

ប្រការ ១៣.~

រាល់ការសម្រេចរបស់អង្គប្រជុំ ដែលចាត់ទុកថាបានការ ត្រូវមានសំឡេងយ៉ាងតិច៥០%+១នៃចំនួនសមាជិក វត្តមានក្នុងអង្គប្រជុំ តាមការលើកដៃ ឬតាមការបោះឆ្នោតសម្ងាត់។ ក្នុងករណីសំឡេងស្មើគ្នា សំឡេងរបស់ប្រធាន អង្គប្រជុំ មានឧត្តមានុភាព។

ប្រការ ១៤.~

រាល់អវត្តមាននៃសមាជិកក្រុមប្រឹក្សាក្នុងការចូលរួមប្រជុំ ត្រូវមានមូលហេតុច្បាស់លាស់ជាលាយលក្ខអក្ស សារអេឡិចត្រូនិច ឬទូរស័ព្ទ។

ករណីអវត្តមាននៃសមាជិកក្រុមប្រឹក្សាលើសពី ២ដងក្នុងការចូលរួមប្រជុំ សម្រាប់អាណត្តិ២ឆ្នាំ ឬលើសពី ៤ដងក្នុងការចូលរួមប្រជុំ សម្រាប់អាណត្តិ៦ឆ្នាំ ដោយគ្មានមូលហេតុច្បាស់លាស់ ចាត់ទុកថាបានបោះបង់បេក្ខភាព ក្នុងការជ្រើសរើសក្រុមប្រឹក្សាអាណត្តិថ្មីដោយស្វ័យប្រវត្តិ។

ប្រការ ១៥.~

ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ត្រូវរៀបចំសន្និបាតជារៀងរាល់ចប់អាណត្តិ២ឆ្នាំម្តង។ សន្និបាតនេះមានការ ចូលរួមពីសមាជិកសមាជិកា នៃគណៈទន្តពេទ្យជាតិ ដោយមានគណៈអធិបតីនិងភ្ញៀវកិត្តិយសមួយចំនួនដែល ក្រុម ប្រឹក្សាគណៈទន្តពេទ្យជាតិយល់ឃើញថាចាំបាច់។

សន្និបាតនេះប្រព្រឹត្តិទៅ ក្រោមអធិបតីភាពរបស់ប្រធានក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ។ របាយការណ៍សកម្ម ភាពក្នុងអាណត្តិ២ឆ្នាំ របាយការណ៍ចំណូលចំណាយ ទិសដៅរបស់ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ សម្រាប់២ឆ្នាំ ខាងមុខ ព្រមទាំងការបោះឆ្នោតជ្រើសរើស សមាជិកការិយាល័យក្រុមប្រឹក្សាអាណត្តិថ្មី ត្រូវបានធ្វើឡើងក្នុងសន្និ បាតនេះ។

ប្រការ ១៦.~

ក្នុងការរៀបចំបោះឆ្នោតជ្រើសរើសសមាសភាព ការិយាល័យអាណត្តិថ្មី ត្រូវបង្កើតគណៈកម្មការបោះឆ្នោតមួយ ដែលមានសមាជិក៣រូប ដែលយល់ព្រមដោយអង្គសន្និបាត។

គណៈកម្មការបោះឆ្នោត ដឹកនាំការបោះឆ្នោតរហូតដល់ពេលប្រកាសលទ្ធផលចុងក្រោយ ដោយប្រគល់ភារៈ កិច្ចជូនប្រធានការិយាល័យក្រុមប្រឹក្សាថ្មី ទើបរំសាយ។ ប្រធានការិយាល័យក្រុមប្រឹក្សាថ្មី ត្រូវធ្វើការប្តេជ្ញាចិត្តក្នុងនាម សមាជិកការិយាល័យរបស់ខ្លួនចំពោះអង្គសន្និបាត។

សមាសភាពការិយាល័យអាណត្តិចាស់ ត្រូវដឹកនាំការងារជាប្រចាំរហូតទទួលបាន អនុក្រឹត្យទទួលស្គាល់ សមាសភាពក្រុមប្រឹក្សា និងការិយាល័យគណៈទន្តពេទ្យជាតិអាណត្តិថ្មី។

ប្រការ ១៧.~

មហាសន្និបាតរបស់ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ត្រូវបានរៀបចំឡើងនៅពេលចប់អាណត្តិ៦ឆ្នាំ។ ដោយ គណៈទន្តពេទ្យកម្ពុជាមានសមាជិកច្រើនទូទាំងប្រទេស ពុំអាចចូលរួមមហាសន្និបាតបានទាំងអស់គ្នា ក្រុមប្រឹក្សា

គណៈទន្តពេទ្យភូមិភាគ និងរាជធានី ខេត្ត ត្រូវចាត់តាំងតំណាងរបស់ខ្លួនចូលរួម នូវចំនួនសមស្របតាមការកំណ
របស់ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ។

មហាសន្និបាតនេះ ត្រូវធ្វើឡើងក្រោមអធិបតីភាពរបស់ប្រធានក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ។ មហាសន្និបា
មានគោលបំណងជូនពត៌មាន ពិគ្រោះយោបល់ អនុម័តគោលការណ៍សំខាន់ៗរបស់គណៈទន្តពេទ្យជាតិ ធ្វើរបា
ការណ៍ស្តីពីសកម្មភាពការងាររយៈពេល៦ឆ្នាំកន្លងមក ហើយលើកទិសដៅការៈកិច្ច ដែលត្រូវអនុវត្តសម្រាប់អាណ
៦ឆ្នាំបន្តទៀត ព្រមទាំងជ្រើសរើសសមាជិកតំណាងអង្គភាព រាជធានី ខេត្ត ដើម្បីបង្កើតការិយាល័យក្រុមប្រឹក្
គណៈទន្តពេទ្យជាតិដាថ្មី។

ប្រការ ១៨.~

មហាសន្និបាតអាចប្រព្រឹត្តិទៅបាន លុះត្រាតែមានសមាជិក៥០%+១ នៃចំនួនសមាជិកដែលត្រូវបានអញ្ជើញ
ឲ្យចូលរួម។

ប្រការ ១៩.~

របៀបរបប និងការប្រព្រឹត្តិទៅនៃការបោះឆ្នោត ត្រូវអនុវត្តតាមខ្លឹមសារដូចមានចែងក្នុងប្រការ១៦នៃបទបញ្ញ
ផ្ទៃក្នុងនេះ។

ជំពូក ៦
ក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ

ប្រការ ២០.~

ក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគប្រជុំជារៀងរាល់២ខែម្តង ក្រោមអធិបតីភាពរបស់ប្រធាន ដើម្បីពិនិត្យ
ពិភាក្សា និងដោះស្រាយការងាររបស់ភូមិភាគ។

ក្នុងករណីពិសេស ប្រធានក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ អាចកោះប្រជុំជាបន្ទាន់ដើម្បីដោះស្រាយបញ្ហា
ដែលកើតមានឡើងដាយថាហេតុ ដូចជាការដោះស្រាយពាក្យបណ្តឹង ពីក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត
ក្នុងភូមិភាគជាដើម។ ក្នុងករណីប្រជុំដោះស្រាយពាក្យបណ្តឹង ឬជាក់វិន័យដល់សមាជិក ការប្រជុំនេះត្រូវអនុវត្តតាម
ខ្លឹមសារដែលមានចែងក្នុងមាត្រា ២២ ដល់ ២៧ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈទន្តពេទ្យកម្ពុជា។

ប្រការ ២១.~

ក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ អាចធ្វើការប្រជុំរួមជាមួយ ក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ក្នុងភូមិ
ភាគ ឬសមាជិកសមាជិកាក្នុងភូមិភាគ ក្នុងករណីប្រធានភូមិភាគ យល់ឃើញថាមានការចាំបាច់។

ប្រការ ២២.~

ក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ ត្រូវរៀបចំសន្និបាតមួយនៅពេលចប់អាណត្តិ៦ឆ្នាំ ដើម្បីធ្វើរបាយការណ៍
បូកសរុបសកម្មភាពការងារ លទ្ធផលដែលសម្រេចបានក្នុរយៈពេល៦ឆ្នាំ លើកទិសដៅការៈកិច្ចដែលត្រូវអនុវត្ត
សម្រាប់អាណត្តិ៦ឆ្នាំបន្តទៀត ព្រមទាំងបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាពេញសិទ្ធិ និងសមាជិកជំនួស
សម្រាប់អាណត្តិ៦ឆ្នាំបន្តទៀត។

សន្និបាតប្រព្រឹត្តិទៅក្រោមការដឹកនាំ របស់ប្រធានក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគសាមី ដោយមានការ
ចូលរួមជាអធិបតី និងកិត្តិយស ពីក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ពីក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្តក្នុង
ភូមិភាគ ពីតំណាងអាជ្ញាធរខេត្ត ពីតំណាងអង្គភាពពាក់ព័ន្ធសំខាន់ៗក្នុងរាជធានី ខេត្ត។

ប្រការ ២៣.~

សន្និបាតអាចប្រព្រឹត្តិទៅបាន លុះត្រាតែមានសមាជិក៥០%+១ នៃចំនួនសមាជិកដែលត្រូវបានអញ្ជើញឲ្យ
ចូលរួម។

ប្រការ ២៤.~

របៀបរបប និងការប្រព្រឹត្តិទៅនៃការបោះឆ្នោត ត្រូវអនុវត្តតាមខ្លឹមសារដូចមានចែងក្នុងប្រការ១៦ នៃបទបញ្ជាផ្ទៃក្នុងនេះ។

ជំពូក ៧
ក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត

ប្រការ ២៥.~

ការិយាល័យក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ធ្វើការប្រជុំជារៀងរាល់ខែ ដើម្បីពិនិត្យតាមដានជាប្រចក្នុងការចុះឈ្មោះរបស់ទន្តពេទ្យ នៅក្នុងបញ្ជីគណៈទន្តពេទ្យ ព្រមទាំងការបង់ប្រាក់ភាគទានរបស់សមាជិក។

ក្នុងករណីចាំបាច់ ការប្រជុំមួយអាចនឹងត្រូវធ្វើឡើង ក្រោមការកោះអញ្ជើញរបស់ប្រធាន ឬអនុប្រធានក្នុងករណីប្រធានអវត្តមាន យ៉ាងតិច១ថ្ងៃមុនពេលប្រជុំ ដោយភ្ជាប់នូវរបៀបវារៈ នៃការប្រជុំច្បាស់លាស់តាមរយលិខិតអញ្ជើញ សារអេឡិចត្រូចនិច ឬទូរស័ព្ទ។

ប្រការ ២៦.~

រាល់ការប្រជុំ ត្រូវដឹកនាំដោយប្រធាន ឬអនុប្រធាន ក្នុងករណីប្រធានអវត្តមាន ដោយមានការប្រគល់សិទ្ធិជាលាយលក្ខអក្សរ សារអេឡិចត្រូចនិច ឬទូរស័ព្ទ ទៅអនុប្រធាន ឬលេខាធិការ ក្នុងករណីមិនអាចធ្វើជាលាយលក្ខអក្សរបាន។

ពេលបញ្ចប់ការប្រជុំនីមួយៗ ប្រធានអង្គប្រជុំត្រូវធ្វើការបូកសរុប និងកំណត់នូវរបៀបវារៈសម្រាប់ការប្រជុំលើកក្រោយ។ រាល់ការប្រជុំត្រូវមានរបាយការណ៍ជាលាយលក្ខអក្សរទុកជាឯកសារ ដោយធ្វើ១ច្បាប់ជូនក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ។

ប្រការ ២៧.~

ក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ត្រូវធ្វើការប្រជុំពីរដង ក្នុងមួយឆ្នាំ នៅខែមករា និងខែកក្កដា លើកលែងតែសន្និបាតបញ្ចប់អាណត្តិ២ឆ្នាំ និងអាណត្តិ៦ឆ្នាំ ដែលត្រូវកំណត់ដោយក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្តនោះ។

ក្នុងករណីចាំបាច់ ការប្រជុំមួយអាចនឹងត្រូវធ្វើឡើង ក្រោមការកោះអញ្ជើញរបស់ប្រធាន ឬអនុប្រធានក្នុងករណីប្រធានអវត្តមាន យ៉ាងតិច១ថ្ងៃមុនពេលប្រជុំដោយភ្ជាប់នូវរបៀបវារៈ នៃការប្រជុំច្បាស់លាស់តាមរយៈលិខិតអញ្ជើញ សារអេឡិចត្រូចនិច ឬទូរស័ព្ទ។

ប្រការ ២៨.~

ការប្រជុំរបស់ក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ធ្វើឡើងក្នុងគោលបំណងផ្សព្វផ្សាយសេចក្តីសម្រេច និង ពត៌មានសំខាន់ៗរបស់ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ។

ប្រការ ២៩.~

ក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ត្រូវរៀបចំសន្និបាតមួយនៅពេលចប់អាណត្តិ៦ឆ្នាំ ដើម្បីធ្វើរបាយការណ៍បូកសរុបសកម្មភាពការងារ លទ្ធផលដែលសម្រេចបានក្នុងរយៈពេល៦ឆ្នាំ លើកទិសដៅការៈកិច្ចដែលត្រូវអនុវត្តសម្រាប់អាណត្តិ៦ឆ្នាំបន្តទៀត ព្រមទាំងបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាពេញសិទ្ធិ និងសមាជិកជំនួស សម្រាប់អាណត្តិ៦ឆ្នាំបន្តទៀត។

សន្និបាតប្រព្រឹត្តិទៅក្រោមការដឹកនាំ របស់ប្រធានក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្តសម្តេចដោយមានការចូលរួមជាអធិបតី និងកិត្តិយស ពីក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ពីក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ក្នុងកូមិភាគ ពីតំណាងអាជ្ញាធរខេត្ត ពីតំណាងអង្គភាពពាក់ព័ន្ធសំខាន់ៗក្នុងរាជធានី ខេត្ត។

ប្រការ ៣០.~

សមាជិកសមាជិកាគណៈទន្តពេទ្យទាំងអស់នៅក្នុងខេត្តសាមី ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងសន្និបាត។ដោ
ឡែកចំពោះរាជធានីភ្នំពេញដែលមានសមាជិកច្រើន ការអញ្ជើញឲ្យចូលរួមសន្និបាត ត្រូវបានកំណត់ដោយការិ
ល័យគណៈទន្តពេទ្យរាជធានីភ្នំពេញ។

ប្រការ ៣១.~

សន្និបាតរបស់ក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត អាចប្រព្រឹត្តិទៅបាន លុះត្រាតែមានសមាជិកចូលរួ
៥០%+១ នៃចំនួនសមាជិកដែលអញ្ជើញឲ្យចូលរួម។

ប្រការ ៣២.~

របៀបរបប និងការប្រព្រឹត្តិទៅនៃការបោះឆ្នោត ត្រូវអនុវត្តតាមខ្លឹមសារដូចមានចែងក្នុងប្រការ១៦ នៃបទបញ្ញ
ផ្ទៃក្នុងនេះ។

ជំពូក ៨
ក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ និង រាជធានី ខេត្ត

ប្រការ ៣៣.~

ក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ និង រាជធានី ខេត្ត ត្រូវរៀបចំសន្និបាតនៅរៀងរាល់ចប់អាណត្តិ២ឆ្នាំម្តង។ សន្និបាតនេះ មានការចូលរួមពីសមាជិកពេញសិទ្ធិ និងសមាជិកជំនួសទាំងអស់របស់ក្រុមប្រឹក្សា។

ប្រការ ៣៤.~

សន្និបាតរបស់ក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ និង រាជធានី ខេត្ត ប្រព្រឹត្តិទៅក្រោមអធិបតីភាពរបស់ប្រធានក្រុមប្រឹក្សារៀងៗខ្លួន និងតំណាងគណៈទន្តពេទ្យជាតិ។ របាយការណ៍ស្តីពីសកម្មភាពការងារចំណូលចំណាយក្នុងអាណត្តិថ្មី ទិសដៅរបស់ក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ និង រាជធានី ខេត្ត សម្រាប់២ឆ្នាំខាងមុខ ត្រូវបានលើកឡើងក្នុងសន្និបាត ព្រមទាំងបោះឆ្នោតជ្រើសរើសសមាជិកការិយាល័យក្រុមប្រឹក្សាអាណត្តិថ្មីបន្តទៀត។

ប្រការ ៣៥.~

សន្និបាតរបស់ក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ និង រាជធានី ខេត្ត អាចប្រព្រឹត្តិទៅបាន លុះត្រាតែមានសមាជិក៥០%+១ នៃចំនួនសមាជិកពេញសិទ្ធិ និងសមាជិកជំនួសចូលរួម។

ប្រការ ៣៦.~

របៀបរបប និងការប្រព្រឹត្តិទៅនៃការបោះឆ្នោត ត្រូវអនុវត្តតាមខ្លឹមសារដូចមានចែងក្នុងប្រការ១៦ នៃបទបញ្ញ
ផ្ទៃក្នុងនេះ។

ជំពូក ៩
ការប្រកបវិជ្ជាជីវៈ

ប្រការ ៣៧.~

ទន្តពេទ្យ ដែលជាសមាជិកសមាជិកា គណៈទន្តពេទ្យកម្ពុជាមានសិទ្ធឈរឈ្មោះបើកៈ

ក.បន្ទប់ពិគ្រោះ និងព្យាបាលជំងឺមាត់ធ្មេញបាន លុះត្រាតែក្រោយពេលបញ្ចប់ការសិក្សា បានអនុវត្តការងារទន្តសាស្ត្រ នៅបណ្តាបន្ទប់ពិគ្រោះ និងព្យាបាលជំងឺមាត់ធ្មេញ ឬ គ្លីនិកពិគ្រោះ និងព្យាបាលជំងឺមាត់ធ្មេញ រយៈពេលមានការទទួលស្គាល់ពីគណៈទន្តពេទ្យកម្ពុជា រយៈពេលពីរឆ្នាំយ៉ាងតិច។

ខ.គ្លីនិកពិគ្រោះ និងព្យាបាលជំងឺមាត់ធ្មេញបាន លុះត្រាតែក្រោយពេលបញ្ចប់ការសិក្សា បានអនុវត្តការងទន្តសាស្ត្រ នៅបណ្តាបន្ទប់ពិគ្រោះ និងព្យាបាលជំងឺមាត់ធ្មេញ ឬ គ្លីនិកពិគ្រោះ និងព្យាបាលជំងឺមាត់ធ្មេ ដែលមានការទទួលស្គាល់ពីគណៈទន្តពេទ្យកម្ពុជា រយៈពេលប្រាំឆ្នាំយ៉ាងតិច។

ប្រការ ៣៨.~

ទន្តពេទ្យគ្រប់រូប ចាំបាច់ត្រូវចូលរួមវគ្គសិក្សាបំប៉នចំណេះដឹងជាប្រចាំ ក្រោមការរៀបចំរបស់មហាវិទ្យាល័យ ទន្តវទនសាស្ត្រ សមាគមទន្តពេទ្យ អង្គការនានា ដោយមានការទទួលស្គាល់ និងកំណត់ពិន្ទុ ពីក្រុមប្រឹក្សគណៈទន្ត ពេទ្យជាតិ។

បែបបទនិងការកំណត់ពិន្ទុ លើវគ្គសិក្សាបំប៉នចំណេះដឹងប្រចាំឆ្នាំ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស ប្រធានក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ។

ជំពូក ១០
អំពីផ្លេកវិន័យ

ប្រការ ៣៩.~

ក្រុមប្រឹក្សាវិន័យថ្នាក់ជាតិ ជាក្រុមមួយដែលត្រូវបានជ្រើសរើសឡើងដោយ សមាជិការិយាល័យក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ស្របតាមមាត្រា៣៣ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈទន្តពេទ្យកម្ពុជា ដើម្បីត្រួតពិនិត្យ វាយតម្លៃ និងដាក់វិន័យដល់ទន្តពេទ្យ ដែលបានប្រព្រឹត្តិខុសឆ្គងវិជ្ជាជីវៈ និងបទបញ្ញត្តិនានារបស់គណៈទន្តពេទ្យកម្ពុជា។

ប្រការ ៤០.~

ក្រុមប្រឹក្សាវិន័យថ្នាក់ជាតិ ធ្វើការប្រជុំពិនិត្យ វាយតំលៃ លើការអនុវត្តកំហុសឆ្គងរបស់ទន្តពេទ្យ ក្រោយពីទទួលបានពាក្យបណ្តឹងទាស់ ពីទន្តពេទ្យសាមុី ពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល ពីប្រធានមន្ទីរសុខាភិបាល ពីព្រះរាជអាជ្ញាអមតុលាការរាជធានី ខេត្ត នូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ។

រាល់សេចក្តីសម្រេច ស្តីពីការដាក់វិន័យរបស់អង្គជុំនុំជម្រះ ត្រូវធ្វើរបាយការណ៍ផ្ទើជូនមក ក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ពាក់ព័ន្ធ និងគណៈទន្តពេទ្យជាតិ។

ប្រការ ៤១.~

អង្គជុំនុំរបស់ក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ មានអំណាចដាក់វិន័យដល់ទន្តពេទ្យ ដែលបានប្រព្រឹត្តិកំហុសឆ្គង ស្របតាមមាត្រា២៥ ២៦ ២៧ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈទន្តពេទ្យកម្ពុជា ដោយសំឡេង ៥០%+១ នៃសមាជិកក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ។

រាល់សេចក្តីសម្រេច ស្តីពីការដាក់វិន័យរបស់អង្គជុំនុំជម្រះ ត្រូវធ្វើរបាយការណ៍ផ្ទើជូនមក ក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ពាក់ព័ន្ធ និងគណៈទន្តពេទ្យជាតិ។

ក្រោយពីទទួលបានសេចក្តីសម្រេច របស់ក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ បើកផ្លូវប្តឹងទាស់ទៅ ក្រុមប្រឹក្សាវិន័យរយៈពេល៣០(សាមសិប)ថ្ងៃ។

ជំពូក ១១
គណៈកម្មការត្រួតពិនិត្យគណនី

ប្រការ ៤២.~

គណៈកម្មការត្រួតពិនិត្យគណនី ត្រូវបានបង្កើតឡើង ដោយក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ស្របតាមមាត្រា ៣៧ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈទន្តពេទ្យកម្ពុជា។ គណៈកម្មការនេះ មានប្រធាន១រូប និងសមាជិកបាន៣

ប្រការ ៤៣.~

គណៈកម្មការត្រួតពិនិត្យគណនី មានភារៈកិច្ចត្រួតពិនិត្យគណនី ការចាត់ចែងប្រើប្រាស់ថវិការបស់ក្រុមប្រឹក្សាគណៈទន្តពេទ្យគ្រប់ជាន់ថ្នាក់។

គណៈកម្មការត្រួតពិនិត្យគណនី អាចត្រួតពិនិត្យមួយដងយ៉ាងតិចក្នុងមួយឆ្នាំ នៅគ្រប់អង្គភាពដោយមិនជូនដំណឹងជាមុននូវគណនី ការចាត់ចែងប្រើប្រាស់ថវិការបស់ក្រុមប្រឹក្សាគណៈទន្តពេទ្យគ្រប់ជាន់ថ្នាក់ បន្ទាប់ពីបានទទួលការអនុញ្ញាត្តិ ឬតាមបញ្ជារបស់ប្រធានក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ។

ប្រការ ៤៤.~

រាល់បំណាច់ឆ្នាំនីមួយៗ គណៈកម្មការត្រួតពិនិត្យគណនី ត្រូវធ្វើរបាយការណ៍អំពីការត្រួតពិនិត្យរបស់ខ្លួនជូនក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ។

ជំពូក ១២
ការបង់ភាគទាន

ប្រការ ៤៥.~

ទន្តពេទ្យ នៅពេលសុំចុះឈ្មោះក្នុងបញ្ជីគណៈទន្តពេទ្យកម្ពុជា ត្រូវបង់ប្រាក់ជូនក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ដែលខ្លួនតាំងនៅប្រកបវិជ្ជាជីវៈ នូវសិទ្ធិចុះឈ្មោះជាសមាជិក ចំនួន២០០.០០០រៀល(ម្ភៃម៉ឺនរៀល) ស្របតាមមាត្រា៣៦ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈទន្តពេទ្យកម្ពុជា។

ប្រការ ៤៦.~

នៅពេលបានចូលជាសមាជិកគណៈទន្តពេទ្យកម្ពុជាហើយ សមាជិកម្នាក់ៗមានកាតព្វកិច្ចបង់ប្រាក់ភាគទានប្រចាំឆ្នាំ ជូនក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ដែលខ្លួនតាំងនៅប្រកបវិជ្ជាជីវៈ។ ប្រាក់ភាគទានប្រចាំឆ្នាំត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ។

ប្រការ ៤៧.~

ចំពោះទន្តពេទ្យបរទេសទាំងអស់ ដែលមានបំណងប្រកបវិជ្ជាជីវៈទន្តសាស្ត្រ នៅព្រះរាជាណាចក្រកម្ពុជាចាំបាច់ត្រូវមកសុំចុះឈ្មោះក្នុងបញ្ជីគណៈទន្តពេទ្យកម្ពុជា។ នៅពេលសុំចុះឈ្មោះ ទន្តពេទ្យបរទេសត្រូវបង់ប្រាក់ជូនក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ដែលខ្លួនតាំងនៅប្រកបវិជ្ជាជីវៈ នូវសិទ្ធិចុះឈ្មោះជាសមាជិកចំនួន ២.០០០.០០០រៀល(ពីរលានរៀល) និងប្រាក់ភាគទានប្រចាំឆ្នាំ ១.២០០.០០០រៀល(មួយលានពីរសែនរៀល)។

ចំពោះទន្តពេទ្យបរទេស ដែលបានផ្តល់គុណប្រយោជន៍ក្នុងវិស័យទន្តសាស្ត្រ នៅព្រះរាជាណាចក្រកម្ពុជាអាចទទួលបានការអនុគ្រោះ លើប្រាក់សុំចុះឈ្មោះ និងប្រាក់ភាគទានប្រចាំឆ្នាំ តាមការសម្រេចរបស់ការិយាល័យក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ។

ប្រការ ៤៨.~

សមាជិក សមាជិកា ដែលមិនបានបង់ប្រាក់ភាគទានប្រចាំឆ្នាំ ហួសកំណត់រយៈពេល១ខែដោយគ្មាន មូលហេតុ ក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្តសាមី ត្រូវធ្វើលិខិតព្រមានជាលើកទី១ និងជាលើកចុងក្រោយ។

ប្រការ ៤៩.~

សមាជិក សមាជិកា ដូចករណីដែលមានចែងនៅប្រការ៤៨ ក្នុងរយៈពេល៦ខែក្រោយការព្រមាន នៅតែមិនព្រមបង់ប្រាក់ភាគទានប្រចាំឆ្នាំ ជូនគណៈទន្តពេទ្យកម្ពុជា ក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្តសាមី ត្រូវធ្វើលិខិតស្នើទៅក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ ដើម្បីពិនិត្យ និងដោះស្រាយ។ ក្នុងករណីមិនបានសម្រេច ក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ ត្រូវធ្វើលិខិតស្នើទៅក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ដោយមានភ្ជាប់នូវមួយនូវកំណត់ហេតុប្រជុំ និងសំណូមពរច្បាស់លាស់ដើម្បីឲ្យ ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិពិនិត្យ និងសម្រេច។

ប្រការ ៤០.~

នៅរៀងរាល់៦ខែម្តង ក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត ត្រូវបង់ថវិកាជូនក្រុមប្រឹក្សាគណៈទន្តពេ
កូមិភាគ១៥%និងក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ៤៥%នៃប្រាក់ភាគទានសរុបដែលទទួលបានពីសមាជិក។ ឯប្រា
៤០%ទៀត ក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត រក្សាទុកដើម្បីចាត់ចែងប្រើប្រាស់សម្រាប់ដំណើរការរបស់ ក្រុ
ប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្តនោះ (មាត្រា៣៥ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈទន្តពេទ្យកម្ពុជា)។

ជំពូក ១៣
ការអនុវត្តន៍

ប្រការ ៤១.~

បទបញ្ជាផ្ទៃក្នុងនេះ ត្រូវបានធ្វើការកែសម្រួល និងអនុម័តជាឯកច្ឆន្ទ នាសម័យប្រជុំពេញអង្គ របស់ក្រុមប្រឹក្
គណៈទន្តពេទ្យជាតិ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥ ។

ប្រការ ៤២.~

ការកែប្រែបទបញ្ជាផ្ទៃក្នុងនេះអាចធ្វើទៅបាន លុះត្រាតែមានសំណើ ពីសមាជិកក្រុមប្រឹក្សាគណៈទន្តពេទ
ជាតិ ៥០% ឬពីសមាជិកការិយាល័យក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ៥(ប្រាំ)រូប និងត្រូវមានការគាំទ្រដោយ
សមាជិកក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ៥០%+១។

ប្រការ ៤៣.~

បទបញ្ជាផ្ទៃក្នុងនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ

ប្រធាន

ឯកឧត្តម.សុខុម រិទ្ធីវុធ

កន្លែងទទួលៈ
.ក្រសួងសុខាភិបាល ដើម្បីជូនជ្រាបជាព័ត៌មាន
.សមាគមទន្តពេទ្យកម្ពុជា
.គ្រប់សមាជិក ក.ទ.ជ
.អគ្គលេខាធិការដ្ឋាន ក.ទ.ជ
.ក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ
.ក្រុមប្រឹក្សាគណៈទន្តពេទ្យរាជធានី ខេត្ត
.ក្រុមប្រឹក្សាវិន័យ
.គណៈកម្មការត្រួតពិនិត្យគណនី
.ដើម្បីផ្សព្វផ្សាយគ្រប់សមាជិក
.ឯកសារ កាលប្បវត្តិ